ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ　　　　　អាងនាមប្រជារាស្ត្រខ្មែរ

លេខ : ១០២　　　　　តុលាការកំពូល

ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤

សាលដីកា

លេខ : ១០

ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | **ឃឹម ប៊ុណ្ណ** | ប្រធាន |
| ២- | លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- | លោក | ប្រាក់ គីមសាន | ចៅក្រម-របាយការណ៏ |
| ៤- | លោក | វៀល មួន | ចៅក្រម |
| ៥- | លោក | សោម សិរីវឌ្ឍ | ចៅក្រម |

ក្រឡាបញ្ជី

លោក ឈាង វិន្ថា

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៨១"ខ"ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ១០២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

***ចោទ*:** ក្រុមជនប្រដាប់អាវុធ , ប្លន់ , មនុស្សឃាត ,បង្ខាំងមនុស្សខុសច្បាប់ , ធ្វើអោយខូចខាតដោយចេតនា និង ភេរវកម្ម ។ ប្រព្រឹត្តបទល្មើសនៅខេត្តកំពត កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៤ និង ខែសីហា ឆ្នាំ១៩៩៤ ផ្តន្ទាទោសតាមមាត្រា៣៦ ,៣៤ ,៣១ ,៣៥ ,៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា២ នៃច្បាប់ស្តីពីអំពើភេរវកម្ម ។

-ជនជាប់ចោទឈ្មោះឈូក រិន ( ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរអតីតយោធា កើតនៅភូមិត្រពាំងស្រែ ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត ក្រុងកែប ។ ទីលំនៅសព្វថ្ងៃភូមិចំការបីផ្លូវភ្នំវល្លិ៍ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកំពត ក្រុងកែប ។ ប្រពន្ធឈ្មោះយ៉ែម-សារី មានកូន០៥នាក់ ឪពុកឈ្មោះឈូក យាន "ស" ម្តាយឈ្មោះព្រៀត លុយ "ស" ចាប់ខ្លួនថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៩៨ ឃុំខ្លួនថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៨ ( នៅក្រៅឃុំ ) ។

-មេធាវី : លោកពុធ ធាវី

-ដើមបណ្តឹងរដ្ឋប្បវេណី :

១-ឈ្មោះប្រាកេ ហ្សង់ក្លូត(ម្ចាស់បណ្តឹងសាទុក្ខ) ជាឪពុកជនរងគ្រោះឈ្មោះហ្សង់ មីហ្សែលប្រាកេ "ស្លាប់" ភេទប្រុស ជនជាតិបារាំង ទីលំនៅសព្វថ្ងៃប្រទេសបារាំង ។

-មានអ្នកបកប្រែលោកប្លែស គីលីយ៉ង់ ជំនួយការអ្នកបកប្រែលោកយូ ផល្លី ។

-មេធាវី : លោកលឹមអេង រតនៈ

២-ឈ្មោះដូរ៉ូធី ស្លេតធី ជាម្តាយជនរងគ្រោះឈ្មោះម៉ាក ល្វេតធី "ស្លាប់" (ជាចុងបណ្តឹងសាទុក្ខ) ជនជាតិអង់គ្លេស ទីលំនៅសព្វថ្ងៃនៅប្រទេសអង់គ្លេស ។ ផ្ទេរសិទ្ធិអោយលោកឆក កូដ៏រ ភេទប្រុស អាយុ៥៦ឆ្នាំ ជនជាតិអាមេរិក សញ្ជាតិអាមេរិកកាំង មុខរបរទីប្រឹក្សាផ្នែកច្បាប់នៃគំរោងរៀបចំដីធ្លីរបស់អង្គការ GTZ ។

-មានអ្នកបកប្រែភាសា លោកស្រីហេង យូឡេង ។

-មេធាវី : គ្មាន

៣-ឈ្មោះភីធីអាន់ថូនី វិលសុន ជាឪពុកជនរងគ្រោះឈ្មោះដាវីត វីលសុន "ស្លាប់" (ជាចុងបណ្តឹងសាទុក្ខ) ជនជាតិអូស្ត្រាលី ទីលំនៅសព្វថ្ងៃនៅប្រទេសអូស្ត្រាលី ។

៤-ឈ្មោះណី ស្រី (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិខ្មែរ នៅផ្ទះលេខ១២១ ផ្លូវ១៨៦ សង្កាត់ទឹកល្អក់ទី៣ ខ័ណ្ឌទួលគោក ក្រុម២១ ក្រុងភ្នំពេញ (ជាប្រពន្ធសពជនរងគ្រោះឈ្មោះសុខ ប៊ុនថា)

-មេធាវី : គ្មាន

៥-ឈ្មោះអ៊ុំ សុជា (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣០ឆ្នាំ នៅភូមិសំបូរ ឃុំរកាក្នុង ស្រុកត្រាំកក់ ខេត្តតាកែវ (ជាប្រពន្ធសពជនរងគ្រោះឈ្មោះសៅ ថា) ។

-មេធាវី : គ្មាន

៦-ឈ្មោះចាន់ សារី (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៤ឆ្នាំ នៅផ្ទះលេខ៧៣$B_2$ ផ្លូវ១៦២ ក្រុម១៤ សង្កាត់ផ្សារដេប៉ូទី១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ (ជាអ្នកការពារខ្សែរថភ្លើង) ។ (សេនាជន) ។

-មេធាវី : គ្មាន

៧-ឈ្មោះសួន សារិន (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៩ឆ្នាំ នៅផ្ទះលេខ៥៧ ផ្លូវ៥៦៦ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ជាតំណាងរាជាយស្ម័យយានកម្ពុជា ។

-មេធាវី : គ្មាន

តាមរបាយការណ៍ស្តីពីមរណៈភាពរបស់លោកម៉ាក ស្លេធ័រ ដែលស្ថានទូតបានទទួលពីទីក្រុងឡុងដុង មកបញ្ជាក់ថា : នៅថ្ងៃទី២៦-០៧-១៩៩៤ លោកស្លេធ័រ និង មិត្តទាំងពីរឈ្មោះដាវីត វិលសុន

ជាជនជាតិអូស្ត្រាលី និង លោកមីសែន ប្រាកេ ជនជាតិបារាំង បានធ្វើដំណើរតាមរថភ្លើងទៅលេងក្រុងព្រះសីហនុ២.៣ថ្ងៃ ហើយវេលាម៉ោង១២.៣០នាទីថ្ងៃនោះ រថភ្លើងក៏ទទួលរងការវាយប្រហាររថភ្លើង ឈប់ភ្លាមក្នុងការជ្រួលច្របល់ឈ្មោះណោរ៉ា បានឃើញខ្មែរក្រហមចាប់ណើ្ដអ្នកទាំងបីចេញឆ្ពោះទៅជំរំភ្នំវល្លិ៍ ឈ្មោះឈូក រិន ជាអ្នកទទួលខុសត្រូវលើការវាយប្រហាររថភ្លើង ។ នៅសប្តាហ៍បន្ទាប់មករូបថត និង កាសែតរបស់អ្នកទាំងបីរូបត្រូវបានបញ្ជូនមកតាមរយៈភ្នាក់ងារបញ្ជាក់ថា : ពួកគាត់រស់នៅក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហម ។ នៅថ្ងៃទី២៨-០៩-១៩៩៤ វេលាម៉ោង៦ព្រឹក អ្នកទាំងបីត្រូវបាននាំចេញពីខ្ទមដោយឈ្មោះនួន ប៉ែត និង អង្គរក្សបីនាក់ ។ បន្តិចក្រោយមកលឺសូរបាញ់ច្រើនគ្រាប់ ហើយឃើញអ្នកទាំងបីទៀត ។ នៅថ្ងៃទី០២-១១-១៩៩៤ ប៉ូលីសអង់គ្លេស និង តំណាងរដ្ឋាភិបាលបារាំង និង អូស្ត្រាលីបានជូនដំណើរដោយកងទ័ពទៅជំរុំ នួន ប៉ែត ត្រូវបានរកឃើញសាកសពអ្នកទាំងបីនៅទីនោះប្រមាណ ៥០០ម៉ែត្រ ខាងត្បូងឈាងខាងលិចមូលដ្ឋានរបស់នួន ប៉ែត ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការក្រុងភ្នំពេញ ថា : ចោទប្រកាន់លើឈ្មោះឈូក រិន ភេទប្រុស អាយុ៤៦ឆ្នាំ ពីបទ ក្រុមជនប្រដាប់អាវុធ , ប្លន់ទ្រព្យសម្បត្តិប្រជាជន មនុស្សឃាតដោយចេតនាគិតទុកជាមុន ,បង្ខាំង មនុស្សខុសច្បាប់ , ធ្វើអោយខូចខាតដោយចេតនានូវទ្រព្យសម្បត្តិសាធារណៈ និង ភេរវកម្ម ប្រព្រឹត្តនៅខេត្តកំពត កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៤ និង ខែសីហា ឆ្នាំ១៩៩៤ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៣៦ ,៣៤ ,៣១ ,៣៥ , ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា២ នៃច្បាប់ស្តីពីអំពើភេរវកម្ម និង មាត្រា៥ នៃក្រិត្យច្បាប់លេខ០២ ក្រ.ច ចុះថ្ងៃទី១៥-០៥-១៩៨០ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៣៤"គ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-មិនយកទោសពៃរ៍ឈ្មោះឈូក រិន ភេទប្រុស អាយុ៤៦ឆ្នាំ ចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់ពីបទ ឃាតកម្មគិតទុកជាមុន , បង្ខាំងមនុស្សខុសច្បាប់ ,អំពើប្លន់ ,ក្រុមជនប្រដាប់អាវុធ , អំពើភេរវកម្ម និង ធ្វើអោយខូចខាតដោយចេតនានូវទ្រព្យសម្បត្តិសាធារណៈ ប្រព្រឹត្តកាលពីថ្ងៃទី២៦-០៧-១៩៩៤ និង ខែ០៨-០៩ ឆ្នាំ១៩៩៤ នៅខេត្តកំពត តាមបញ្ញត្តិមាត្រា៥ នៃច្បាប់ស្តីអំពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យអោយនៅក្រៅច្បាប់ ។

២-បង្គាប់អោយដោះលែងជាបន្ទាន់ឈ្មោះឈូក រិន ភេទប្រុស អាយុ៤៦ឆ្នាំ ប្រសិនបើឈ្មោះនេះមិនត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

៣-ទុកសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងរដ្ឋប្បវេណីទៅតុលាការរដ្ឋប្បវេណី ។

៤-ប្រគល់សំភារៈដែលបានដកហូតពីឈ្មោះឈូក រិន អោយទៅម្ចាស់ដើមវិញ ។

៥-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ សំរេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣៦"គ" ចុះថ្ងៃទី២០-០៧-២០០០ របស់លោកព្រះរាជអាជ្ញារង អមតុលាការក្រុងភ្នំពេញ និង បណ្តឹងឧទ្ធរណ៍លេខ៣៧"គ" ចុះថ្ងៃទី២០-០៧-២០០០ របស់លោកមេធាវី យឹម សារី តំណាង ប្រាកេ ហ្សង់ក្លូត ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៣៤"គ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៨"គ" ចុះថ្ងៃទី១២-០៩-២០០០ របស់លោកមេធាវីពុធ ធារី ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៣៤"គ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី៣ នៃសេចក្តីវិនិច្ឆ័យ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : រឿងនេះ អយ្យការក្រុងភ្នំពេញ បានចោទប្រកាន់មាន៦បទល្មើស គឺបទក្រុមជនប្រដាប់អាវុធ ,ប្លន់ ,បង្ខាំងមនុស្សខុសច្បាប់ , ធ្វើអោយខូចខាតដោយចេតនា , បទភេរវកម្ម និង បទមនុស្សឃាត ប៉ុន្តែតុលាការក្រុងភ្នំពេញបានសំរេចមិនយកទោសពៃរ៍លើជនជាប់ចោទឈ្មោះឈូក រិន មិនត្រឹមត្រូវទេ បើយើងយោងទៅលើច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យអោយនៅក្រៅច្បាប់នោះ ។ ហើយព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញបានចោទរួមទាំងបីបទល្មើសតែម្តង គឺមានបទប្លន់ ,បទធ្វើអោយខូចខាតដោយចេតនា និង បទភេរវកម្ម និង បទល្មើសផ្សេងៗទៀត ទុកជូនតុលាការអង្កេតបន្ថែមទៀត ។ សូមអោយក្រុមប្រឹក្សាផ្តន្ទាទោសជនល្មើសឈ្មោះឈូក រិន ដូចដែលអយ្យការក្រុងភ្នំពេញបានចោទប្រកាន់រួចនោះ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១១"ខ" ចុះថ្ងៃទី០៦-០៩-២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ក/-ទទួលបណ្តឹងឧទ្ធរណ៍លេខ៣៦"គ" ចុះថ្ងៃទី២០-០៧-២០០០ របស់ព្រះរាជ-អាជ្ញារង អមតុលាការក្រុងភ្នំពេញ និង លេខ៣៧"គ" ចុះថ្ងៃទី២០-០៧-២០០០ របស់លោកយឹម សារី ជាមេធាវី និង ជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះប្រាកេ ហ្សង់ក្លូត ទុកជាត្រឹមត្រូវតាមទំរង់ នជិ គតិច្បាប់ ។

ខ/-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ៤៨"គ" ចុះថ្ងៃទី១២-០៩-២០០០ របស់លោកពុធ ធារី ជាមេធាវីរបស់ជនជាប់ចោទទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ក/-ទទួលស្គាល់លោកទូច ឆេងតិច ជាមេធាវី និង ជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះប្រាកេ ហ្សង់ក្លូត ទុកជាត្រឹមត្រូវតាមច្បាប់ ។

២/-ទទួលស្គាល់លោកអៀ សុភាព ជាមេធាវី និង ជាតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះអ្នកស្រីដូ៉រូធី ស្ទេធី ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ៣៤"គ" ចុះថ្ងៃទី១៨-០៧-២០០០ របស់តុលាការក្រុងភ្នំពេញ ចោលជាអាសារបង់ ។

៤-អោយឈ្មោះឈូក រិន រួចផុតពីបទចោទ : បទក្រុមជនប្រដាប់អាវុធ ប្រព្រឹត្តនៅខេត្តកំពត កាលពីថ្ងៃទី២៦-០៧-១៩៩៤ ដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា៣៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥-ផ្តន្ទាទោសឈ្មោះឈូក រិន ដាក់ពន្ធនាគារអស់មួយជីវិតពីបទ : ភេរវកម្ម តាមមាត្រា២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម ។ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៦-ទុកសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមានផលប្រយោជន៍ពាក់ព័ន្ធនិងរឿងក្តីនេះ ប្តឹងទាមទារជាបទរដ្ឋប្បវេណីនូវសំណងខូចខាតតាមទំហំនៃព្យសនកម្មរៀង១ខ្លួនទៅតុលាការរដ្ឋប្បវេណីនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

សាលដីកានេះជំនុំជំរះជាសាធារណៈកាលពីថ្ងៃទី២៨-០៨-២០០២ និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៦-០៩-២០០២ កំបាំងមុខជនជាប់ចោទ មេធាវីរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះអ៊ុំ សុជា , ណី ស្រី , សួន សារិន , ស្ទេធ័រ ដូ៉រូធី និង ភីធ័រ អាន់ថូរិលសុន និង តំណាងរាជាយស្ម័យ-យានកម្ពុជា ចំពោះមុខឈ្មោះប្រាកេ ហ្សង់ក្លូត ,ឈ្មោះទូច នេងតិច និង លោកអៀ សុភាពមេធាវីតំណាងអ្នកស្រីស្ទេធ័រ ដូ៉រូធី បើកផ្លូវប្តឹងទាស់១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីសាលដីកាកំបាំងមុខ និង បើកផ្លូវប្តឹងសាទុក្ខ០២ខែ គិតចាប់ពីថ្ងៃផុតកំណត់ប្តឹងទាស់ចំពោះគូក្តីកំបាំងមុខ និង គិតពីថ្ងៃប្រកាសសាលដីកាចំពោះគូក្តីចំពោះមុខ ។

-បានឃើញបណ្តឹងទាស់លេខ២១ ចុះថ្ងៃទី០៦-១២-២០០២ របស់ឈ្មោះឈូក រិន ប្តឹងមិនសុខពីសាលដីកាព្រហ្មទណ្ឌលេខ១១"ខ" ចុះថ្ងៃទី០៦-០៩-២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី១(ក) ទី១(ខ) ទី៣ ,ទី៥ និង ទី៦ នៃសាលដីកាទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៨១"ខ" ចុះថ្ងៃទី០៥-១១-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១-ទទួលបណ្តឹងទាស់លេខ២១ ចុះថ្ងៃទី០៦-១២-២០០២ របស់ជនជាប់ចោទឈ្មោះឈូក រិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាកំបាំងមុខលេខ១១"ខ" ចុះថ្ងៃទី០៦-០៩-២០០២ របស់សាលា-ឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧-១០-២០០៣ ចំពោះមុខជនជាប់ចោទ.មេធាវីការពារជនជាប់ចោទ .មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី និង ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះហ្សង់ ក្លូតប្រាកេ .សួន សារិន តំណាងរាជាយស្ម័យយាន កំបាំងមុខដូរ៉ូធី ស្លេធីរ .អាន់ថូនី រិលសុន . ណី ស្រី .អ៊ុំ សុជា និង ចាន់ សារី ប្រកាសជាសាធារណៈនៅថ្ងៃទី០៥-១១-២០០៣ ចំពោះមុខមេធាវីការពារជនជាប់ចោទ មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីកំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណីតែចាត់ទុកជាចំពោះមុខ ។ បើកផ្លូវសាទុក្ខ០២ ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១៣៨ ចុះថ្ងៃទី០៨-១២-២០០៣ របស់លោកលឹម អេងរតនៈ មេធាវីតំណាងអោយលោកហ្សង់ក្លូត ប្រាកេ ជាឪពុកជនរងគ្រោះឈ្មោះហ្សង់ មីហ្សែលប្រាកេ ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៨១"ខ" ចុះថ្ងៃទី០៥-១១-២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសំរេចស្តីពីការទាមទារសំណងជំងឺចិត្តរបស់ភាគីរបស់ខ្លួន ។

-បានឃើញបណ្តឹងសាទុក្ខលេខ១៤៧ ចុះថ្ងៃទី២៥-១២-២០០៣ របស់ឈ្មោះឈូក រិន ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៨១"ខ" ចុះថ្ងៃទី០៥-១១-២០០៣ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល លើកលែងតែចំណុចទី៤ ពុំប្តឹង ។

-បានស្តាប់របាការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :

+បណ្តឹងសាទុក្ខធ្វើក្នុងកំណត់ច្បាប់

+តម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការលើកលែងតែសំណង ។

-បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និង សារណារបស់ជនជាប់ចោទឈ្មោះឈូក រិន ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ប្រាកេ ហ្សង់ក្លូត (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ថា : បានជាខ្ញុំបាទប្តឹងសាទុក្ខ ព្រោះសាលដីកាសាលាឧទ្ធរណ៍ពុំបានសំរេចអំពីសំណងរដ្ឋប្បវេណីអោយខ្លួន ហើយទុកសិទ្ធិអោយខ្លួនទៅប្តឹងនៅតុលាការរដ្ឋប្បវេណី ។ ចំពោះរឿងនេះខ្លួនសូមអោយតុលាការកំពូលសំរេចតម្កល់សាលដីកាសាលាឧទ្ធរណ៍ និង សូមអោយតុលាការកំពូលសំរេចអំពីសំណងរដ្ឋប្បវេណីតែម្តង ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះឆក កូជ័រ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ខ្ញុំបាទ ឆក កូជ័រ ទទួលសិទ្ធិពីឈ្មោះដូរ៉ូធី ស្លេតធី ជាម្តាយជនរងគ្រោះឈ្មោះម៉ាក ស្លេតធី ខ្ញុំសូមបញ្ជាក់ថា ការវាយប្រហារខ្សែរថភ្លើងកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៤ និងសម្លាប់ជនបរទេស ០៣នាក់ កាលពីខែសីហា ឆ្នាំ១៩៩៤ គឺមានឈ្មោះឈូក រិន . នួន ប៉ែត .វិត វន និង សំ ប៊ិត ។ រីឯកន្លែងកើតហេតុ គឺនៅភូមរនេស ឃុំពងទឹក ស្រុកកំពង់ត្រាច ខេត្តកំពត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់យោធាដឹកនាំដោយឈ្មោះឈូក រិន ហើយឈ្មោះនេះក៏បានប្រមូលកំលាំងសហការជាមួយកំលាំង សំ ប៊ិត

និង វិត វន ដើម្បីវាយផ្តាច់ខ្សែរថភ្លើង ក្រោមបញ្ជារបស់ សំ ប៊ិត និង វិត វន។ សូមអោយតុលាការកំពូល តម្កល់សាលដីកាសាលាឧទ្ធរណ៍ និង សំរេចអំពីសំណងរដ្ឋប្បវេណីអោយខ្លួនចំនួន២៥.០០០ដុល្លាអាមេរិក ហើយសំណងនេះវាប្រហាក់ប្រហែលនឹងជនជាតិខ្មែរដែរ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះសួន សារិន (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ខ្លួនសូមឯកភាពតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះប្រាកេ ហ្សង់ក្លូត និង ឈ្មោះឆក កូជ័រ និង សូមអោយតុលាការសំរេចអំពីសំណងខូចខាតទ្រព្យសម្បត្តិសាធារណៈចំនួន២១លាន រៀល ហើយនឹង សំណងជំងឺចិត្តដល់ប្រពន្ធសាកសព៧២នាក់ចំនួន២០.០០០ដុល្លាអាមេរិក ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកលឹមអេង រតនៈ ជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះប្រាកេ ហ្សង់ក្លូត នៅពេលជំនុំជំរះថា : ការពួនស្ទាក់វាយខ្សែរថភ្លើងកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៤ និង សម្លាប់ជនបរទេស០៣នាក់ កាលពីខែសីហា ឆ្នាំ១៩៩៤ គឺមានឈ្មោះឈូក រិន ជាអ្នកបញ្ជូនកំលាំងចំនួន ២០នាក់ ទៅចូលរួមជាមួយឈ្មោះនួន ប៉ែត វិត វន និង សំ ប៊ិត ក្រោមការបញ្ជារបស់ សំ ប៊ិត និង វិត វន ការពួកស្ទាក់នេះ គឺជាអំពើប្លន់យកទ្រព្យសម្បត្តិប្រជាជន ចាប់ប្រជាជន និង ជនបរទេសទាមទារយក ប្រាក់ ។ កន្លែងកើតហេតុនៅស្រុកកំពង់ត្រាច ដែល ឈូក រិន ជាអ្នកគ្រប់គ្រង ។ សូមអោយក្រុមប្រឹក្សា ជំនុំជំរះពិចារណាតម្កល់សេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ និង សូមអោយតុលាការកំពូលសំរេចអំពីសំណង ដល់កូនក្តីរបស់ខ្លួនចំនួន៤៥ម៉ឺនដុល្លាអាមេរិក ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកពុធ ធាវី ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះឈូក រិន នៅពេលជំនុំជំរះថា : កូនក្តីរបស់ខ្លួនគប្បីរួចផុតពីការផ្តន្ទាទោស តាមច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជា-ធិបតេយ្យអោយនៅក្រៅច្បាប់ ព្រោះថាច្បាប់នេះសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៤ ហើយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានចេញលិខិតលេខ៧៣២ ព្រទ.រប៩៥ និយាយពីគោល-ការណ៍ចំពោះខ្មែរក្រហមចូលមកសារភាពក្រោយរយៈពេលអនុគ្រោះ៦ខែ ដែលត្រូវបានចប់នៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៥ ហើយកូនក្តីរបស់ខ្លួនបានប្រព្រឹត្តអំពើល្មើសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៤ គឺនៅ ក្នុងចន្លោះពេលអនុគ្រោះទោស៦ខែ ។ ការដែលសាលាឧទ្ធរណ៍សំរេចផ្តន្ទាទោសកូនក្តីរបស់ខ្លួនឈ្មោះ ឈូក រិន តាមច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្មជាការពុំត្រឹមត្រូវទេ ដោយហេតុថា កូនក្តីរបស់ខ្លួន ជាខ្មែរក្រហម ឬ កម្ពុជាប្រជាធិបតេយ្យតាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយក៏មានអង្គការសហ-ប្រជាជាតិទទួលស្គាល់ ។ កងកម្លាំងកម្ពុជាប្រជាធិតេយ្យ គឺដណ្តើមអំណាចផ្តួលរំលំអំណាច មិនមែន ភេរវកម្មទេ និងនៅទូទាំងប្រទេស គឺជាតំបន់អសន្តិសុខទាំងអស់ ។ សូមក្រុមប្រឹក្សាជំនុំជំរះតុលាការ កំពូល បដិសេធការទាមទារសំណង និង បដិសេធសាលាដីកាសាលាឧទ្ធរណ៍ រួចបង្វិលសំណុំរឿងទៅ សាលាឧទ្ធរណ៍វិញ ដើម្បីចាត់ការអំពីសំណងរដ្ឋប្បវេណីឡើងវិញ ព្រោះថាតុលាការកំពូលជំនុំជំរះតែទៅ លើអង្គច្បាប់ មិនជំនុំជំរះទៅលើអង្គហេតុទេ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលសាវនាការថា : ចំពោះការអនុគ្រោះ៦ខែ គឺ និយាយពីការប្រព្រឹត្តមុនច្បាប់ចូលជាធរមាន មិនមែននិយាយក្រោយច្បាប់ចូលជាធរមាននោះទេ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយរបស់លោកហ្សង់ក្លូត ប្រាក់កេ សារណារបស់ឈ្មោះឈូក រិន ចម្លើយរបស់តំណាងលោកស្រីដូរ៉ូធី ស្ទេតធ័រ ចម្លើយតំណាងអង្គភាពអយ្យស្ម័យយាន និង សេចក្តីសន្និដ្ឋានរបស់ មេធាវី របស់ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីរបស់ជនជាប់ចោទ ។

- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៣៨ ចុះថ្ងៃទី៨-១២-២០០៣ របស់លោកលឹមអេងរតនៈ និង បណ្តឹងសាទុក្ខលេខ១៤៧ ចុះថ្ងៃទី២៥-១២-២០០៣ របស់ឈ្មោះឈូក រិន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការរៀបចំតាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទរួមមានឈ្មោះនួន ប៉ែត និង ឈូក រិន និងចម្លើយសាក្សីដែលជាអតីតខ្មែរក្រហម និង ចម្លើយសាក្សីជាជនរងគ្រោះ ជនដែលទទួលខុសត្រូវខ្ពស់ និង សំខាន់ជាងគេក្នុងការវាយប្រហាររថភ្លើងកាលពីថ្ងៃទី២៦-៧-១៩៩៤ និង សម្លាប់ជនបរទេស៣នាក់ កាលពីខែសីហា ឆ្នាំ១៩៩៤ គឺមានឈ្មោះនួន ប៉ែត ,ឈូក រិន ,វិត វន និង សំ ប៊ិត ។

-យល់ឃើញថា ទីកន្លែងកើតហេតុ គឺភូមិរនេស ឃុំពងទឹក ស្រុកកំពង់ត្រាច ខេត្តកំពត ស្ថិតក្រោមការគ្រប់គ្រងរបស់យោធាដឹកនាំដោយឈ្មោះឈូក រិន ។

-យល់ឃើញថា ចម្លើយរបស់ឈ្មោះឈូក រិន នៅចំពោះមុខចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា កំលាំងរបស់ខ្លួនមួយក្រុមបានចូលរួមវាយស្ទាក់ខ្សែរថភ្លើង ហើយចម្លើយរបស់ឈ្មោះនួន ប៉ែត ក៏បានបញ្ជាក់ដែរថា ឈ្មោះឈូក រិន ជាជនពិការ តែបានប្រមូលកំលាំងអោយសហការជាមួយកំលាំង សំ ប៊ិត និង វិត វន ដើម្បីវាយផ្តាច់ខ្សែរថភ្លើង ក្រោមបញ្ជារបស់ឈ្មោះសំ ប៊ិត និង វិត វន ។

-យល់ឃើញថា សាក្សីឈ្មោះចាន់ សារ៉េត អតីតអនុបញ្ជាការវរៈសេនាតូចយោធាខ្មែរក្រហម បានឆ្លើយចំពោះមុខចៅក្រមស៊ើបអង្កេតថា ខ្លួនបានទទួលបញ្ជាពីប្រធានវរៈសេនាតូចដើម្បីអោយទៅទទួលជនបរទេស៣រូប ជាជនជាតិអឺរ៉ុប ពីអង្គរក្សរបស់ ឈូក រិន ដែលមានគ្នាបួននាក់ អ្នកទាំង៤នាក់បានប្រាប់ខ្លួនថា ឈ្មោះឈូក រិន អោយនាំជនបរទេសទាំង៣នាក់ទៅប្រគល់អោយឈ្មោះវិត វន ។

-យល់ឃើញថា សាក្សីបំភ្លឺឈ្មោះចាន់ សារី ដែលជាជនរងគ្រោះបានឆ្លើយថា ពេលចូលវាយខ្លួន ឃើញឈ្មោះឈូក រិន ជាអ្នកបញ្ជាទ័ព ខ្លួនស្គាល់ ឈូក រិន ដោយសារប្រជាជននៅទីនោះប្រាប់ ពេលចុះស្លងស្រូវ ខ្លួនឮកូនចៅរបស់ ឈូក រិន ដែលការពារពួកខ្លួនប្រាប់ថា ឈ្មោះឈូក រិន ជាអ្នកចុះដឹកនាំកម្លាំងស្ទាក់រទេះភ្លើងដោយផ្ទាល់ ។

-យល់ឃើញថា របាយការណ៍លេខ០១៦ រអយក.រប ចុះថ្ងៃទី០៤-០២-១៩៩៩ របស់អង្គភាពរាជាយស្ម័យយានកម្ពុជា ជូនតុលាការថា ការវាយប្រហាររបស់ពួកឧទាមខ្មែរក្រហមកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៤ បណ្តាលអោយបាត់បង់អាយុជីវិតមនុស្សចំនួន១៣នាក់ ក្នុងនោះមានជនបរទេសចំនួន០៣នាក់ សម្លាប់ក្រោយពេលគៀរ និងបណ្តាលអោយអ្នកដំណើរមួយចំនួនធំត្រូវរបួសធ្ងន់ និងស្រាល និង ខូចខាតសំភារៈយាន ផ្លូវដែក ឧបករណ៍សំភារៈលើខ្សែរថភ្លើង សរុបទឹកប្រាក់ចំនួន២១លានរៀល ។

-យល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះឈូក រិន ពីបទឃាដកម្មដោយចេតនាគិតទុកជាមុន ធ្វើឱ្យខូចខាតដោយចេតនានូវទ្រព្យសម្បត្តិអ្នកដទៃ ប្លន់ , បង្ខាំងមនុស្សខុសច្បាប់ និង ភេរវកម្មប្រព្រឹត្តនៅខេត្តកំពត កាលពីថ្ងៃទី២៦-៧-១៩៩៤ និងកាលពីខែសីហា ឆ្នាំ១៩៩៤ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៣១ ,៥២ ,៣៤ និង ៣៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍មិនបានសំរេចអំពីសំណងរដ្ឋប្បវេណី ហើយទុកសិទ្ធិនេះឱ្យជនរងគ្រោះទៅប្តឹងនៅតុលាការរដ្ឋប្បវេណីនោះ គឺជាការបំពានទៅនឹងមាត្រា១៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ ហើយការដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសំណូមពរឱ្យតុលាការកំពូលសំរេចនៅពេលនេះ តុលាការអង្គច្បាប់ពុំអាចពិចារណាបានឡើយ ។

-យល់ឃើញថា ការដែលតំណាងអោយអ្នកស្រីដូរ៉ូធី ស្វេតធ័រ និង អង្គភាពអយ្យស្ម័យយាន ទាមទារសំណងជម្ងឺចិត្តនៅពេលនេះ តុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះសាម៉ីខ្លួនពុំបានប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ទេ ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទលើកឡើងថា កូនក្តីលោកគប្បីរួចផុតពីការផ្តន្ទា-ទោសតាមច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យអោយនៅក្រៅច្បាប់នោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះថា អំពើល្មើសកើតនៅថ្ងៃទី២៦-៧-១៩៩៤ គឺក្រោយច្បាប់នេះចូលជាធរមាន ហើយច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

-យល់ឃើញថា បទល្មើសដែលក្រុម ឈូក រិន បានប្រព្រឹត្តជាបទល្មើសព្រហ្មទណ្ឌសាមញ្ញ ដូច្នេះត្រូវអនុវត្តតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ដូចការកំណត់នៃមាត្រា៣ នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យ ឱ្យនៅក្រៅច្បាប់ ហើយការដែលសាលាឧទ្ធរណ៍សំរេចផ្តន្ទាទោសឈ្មោះឈូក រិន តាមច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម ជាការត្រឹមត្រូវហើយ ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីលោកភីធី អងគូនីវិលសុន .អ្នកស្រីណៃ ស្រី .អ៊ុំ សុជា និង លោកចាន់ សារី ពុំបានប្តឹងសាទុក្ខមកតុលាការកំពូលទេ ហើយក៏ពុំបានមកចូលរួមសវនាការនេះដែរ ដូច្នេះ តុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា ឈ្មោះឈូក រិន បានជូនសារណាមកតុលាការកំពូល ហើយពុំបានមកចូលរួម សវនាការនេះទេ ប៉ុន្តែមេធាវីរបស់ឈ្មោះនេះបានមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំង មុខឈ្មោះឈូក រិន ប៉ុន្តែចាត់ទុកជា ចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៨១"ខ" ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ លើកលែង ចំណុចស្តីពីសំណងជម្ងឺចិត្ត ។

## ហេតុដូច្នេះ

*វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ហ្សង់ភ្លូត ប្រាកេ តំណាង អ្នកស្រី ដូវូធី ស្វេតជ័រ តំណាងអង្គភាពអយ្យស្ម័យយានកម្ពុជា កំបាំងមុខជនជាប់ចោទ ឈូក រិន ដើមបណ្តឹងរដ្ឋប្បវេណី លោកភីធី អង់គូនីវិលសុន អ្នកស្រីណៃ ស្រី អ្នកស្រីអ៊ុំ សុជា លោកចាន់ សារី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។*

១-ទទួលបណ្តឹងសាទុក្ខលេខ១៣៨ ចុះថ្ងៃទី០៨-១២-២០០៣ របស់លោកលឹមអេង រតនៈ ទុក ជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលបណ្តឹងសាទុក្ខលេខ១៤៧ ចុះថ្ងៃទី២៥-១២-២០០៣ របស់ឈ្មោះឈូក រិន ទុកជាត្រឹម ត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

៣-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨១"ខ"ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងចំណុចទី៦ នៃសាលដីកាព្រហ្មទណ្ឌលេខ១១"ខ" ចុះថ្ងៃទី០៦-៩-២០០២ របស់ សាលាឧទ្ធរណ៍ ដែលត្រូវទុកជាមោឃៈ ។

៤-បង្គាប់អោយចាប់ខ្លួនឈ្មោះឈូក រិន មកដាក់ពន្ធនាគារតាមចំណុចទី៥ នៃសាលដីកា ព្រហ្មទណ្ឌលេខ១១"ខ" ចុះថ្ងៃទី០៦-៩-២០០២ របស់សាលាឧទ្ធរណ៍វិញ ។

៥-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ១០២ ចុះថ្ងៃទី២៣-៨-២០០៤ របស់តុលាការកំពូលទៅ សាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះត្រង់ចំណុចទី៦នៃសាលដីកាព្រហ្មទណ្ឌលេខ១១"ខ" ចុះថ្ងៃទី០៦-៩-២០០២ របស់សាលាឧទ្ធរណ៍ ស្តីពីសំណងជម្ងឺចិត្តជាថ្មីឡើងវិញ ។

៦-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥ ។